00843081

E225

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 09 / 2012
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២

ជូនចំពោះ: ភាគីទាំងអស់នៃសំណុំរឿង ០០២

ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ: សេចក្ដីសម្រេចស្ដីពីការបង្ហាញឯកសារជាក់លាក់មួយចំនួន

កាលពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចដោយផ្ទាល់មាត់មួយស្ដីពីការបង្ហាញឯកសារជាក់លាក់មួយចំនួនរបស់មេធាវីការពារជនជាប់ចោទ នួន ជា។ នៅពេលនេះ អង្គជំនុំជម្រះសូមផ្ដល់សំអាងហេតុពេញលេញដើម្បីគាំទ្រសេចក្ដីសម្រេចដោយផ្ទាល់មាត់ខាងលើនេះ៖

ឯកសារ D366/7.1.564៖

អង្គជំនុំជម្រះទទួលស្គាល់ថា អង្គជំនុំជម្រះចាំបាច់ត្រូវបញ្ជាក់បន្ថែមអំពីការលើកឡើងរបស់លោកចៅក្រមប្រធានអង្គជំនុំជម្រះ ទៅកាន់មេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា។ លោកប្រធានអង្គជំនុំជម្រះបានមានប្រសាសន៍ថា "អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យលោកដកស្រង់បែបខ្លួតយកមកសួរសាក្សីទេ។ លោកអាចយក ខ្លឹមសារនៃឯកសារនោះមកសួរដេញដោលសាក្សីបាន" (ប្រតិចារឹក, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ៣៧)។ ដោយហេតុថាឯកសារខាងលើត្រូវបានដាក់នៅចំពោះ

00843082

មុខអង្គជំនុំជម្រះរួចហើយនោះ ការដកស្រង់ឯកសារនេះដោយពុំមានកំហិត (ឲ្យតែមានភាពពាក់ព័ន្ធ) អាចអនុញ្ញាតឲ្យធ្វើទៅបាន។ យ៉ាងណាក៏ដោយ មេធាវីការពារជនជាប់ចោទ នួន ជា ហាក់ដូចជាបានប្រើប្រាស់ខ្លឹមសារនៃឯកសារនេះដើម្បីសួរសំណួរជាច្រើនទៅសាក្សី។ ហេតុដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីការពារជនជាប់ចោទ នួន ជា ដកស្រង់ពីឯកសារនេះ ប៉ុន្តែតែក្នុងករណីដែលមេធាវីការពារជនជាប់ចោទ នួន ជា មានសំណួរបន្ថែមទៀតដើម្បីសួរទៅសាក្សី ប្រសិន បើមេធាវីការពារក្តីមានបំណងធ្វើដូច្នេះនោះ។ មេធាវីការពារក្តីពុំអាចលើកប្រធានបទទាំងឡាយណាដែលត្រូវបានពិភាក្សារួចហើយបានឡើយ ជាពិសេសនៅពេលដែលសំណួរទាំងនេះត្រូវបានអង្គជំនុំជម្រះយល់ថាពុំពាក់ព័ន្ធ ឬដដែលៗ។

ឯកសារ D22/185.5៖

បញ្ហានេះកើតឡើងដោយសារតែឯកសារនេះពុំត្រូវបានបង្ហាញនៅលើអេក្រង់កុំព្យូទ័រ និងត្រូវបានដកយកពីសាក្សី។ មេធាវីការពារក្តីពុំត្រូវបានកំហិតលើការប្រើប្រាស់ឯកសារនេះក្នុងការសួរសំណួរឡើយ ហើយឯកសារនេះត្រូវបានដកស្រង់ជាច្រើនដង។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ថា មិនចាំបាច់ត្រូវអនុញ្ញាតឲ្យមេធាវី ការពារក្តីសួរសំណួរបន្ថែមទៀតលើបញ្ហានេះឡើយ។

ឯកសារ E3/1435៖

ឯកសារនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ប៉ុន្តែពុំត្រូវបានបង្ហាញលើអេក្រង់កុំព្យូទ័រ និងត្រូវបានយកពីសាក្សី។ ឯកសារនេះមានបញ្ជីឈ្មោះសមាជិករដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្រោយពេលមានសេចក្តីសម្រេចរបស់សភាតំណាងប្រជាជនកម្ពុជានៅខែ ធ្នូ ឆ្នាំ ១៩៧៩ (ក្នុងបញ្ជីឈ្មោះនោះ លោក គាត ឈន់ ត្រូវបានលើកឡើងថាជារដ្ឋមន្ត្រីខុទ្ទកាល័យនាយករដ្ឋមន្ត្រី)។ ក្នុងអំឡុងពេលនៃការសួរសំណួរ មេធាវីការពារក្តី បានដកស្រង់ឈ្មោះសមាជិករដ្ឋាភិបាលទាំងអស់ពីក្នុងបញ្ជីឈ្មោះនោះ។ ហេតុដូច្នេះ មេធាវីការពារក្តីពុំត្រូវបាន កំហិតលើការប្រើប្រាស់ឯកសារនេះឡើយ គ្រាន់តែនៅពេលនោះមានសេចក្តីសម្រេចមួយដែលចេញដោយប្រធានអង្គជំនុំជម្រះ អំពីភាពពាក់ព័ន្ធនៃសំណួរផ្អែកលើឯកសារខាងលើនេះប៉ុណ្ណោះ ហើយដែលសេចក្តី សម្រេចនោះត្រូវបានតវ៉ានាពេលនោះផងដែរ។ (សាក្សីត្រូវបានសួរថាតើ តាមដែលគាត់បានដឹង បញ្ជីឈ្មោះនេះ បានពិពណ៌នាត្រឹមត្រូវអំពីសមាសភាពរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណា ហើយប្រធានអង្គជំនុំ ជម្រះបានសម្រេចថា សាក្សីពុំត្រូវឆ្លើយសំណួរនេះឡើយ ដោយហេតុថាសំណួរនេះពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ទេ) (ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ៣៥)។ មេធាវី

00843083

ការពារក្តីបាន ជំទាស់ទៅនឹងការសម្រេចនេះ ដោយបានអះអាងថា ឯកសារនេះត្រូវបានសហព្រះរាជអាជ្ញាប្រើប្រាស់ក្នុងការសួរសំណួររបស់ខ្លួនទៅសាក្សី ឈ្មោះ ស គឹមល្អុត (ដែលតាមបញ្ជីឈ្មោះនេះ គាត់ជារដ្ឋលេខាធិការក្រសួង ផ្គត់ផ្គង់ និងដឹកជញ្ជូន)។ ជំនួសមុខឱ្យអង្គជំនុំជម្រះសាលាដំបូង ចៅក្រម Lavergne បានបញ្ជាក់ថា ការ អនុញ្ញាតឱ្យសួរសំណួរនេះ អាស្រ័យទៅលើភាពពាក់ព័ន្ធរបស់សំណួរ (ប្រតិចារឹក, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ៩៦)។ មេធាវីការពារជនជាប់ចោទ នួន ជា មិនចាំបាច់សួរសំណួរបន្ថែមលើប្រធានបទនេះ ឡើយ។